UNITED NATIONS
OFFICE OF THE HIGH COMMISSIONER
FOR HUMAN RIGHTS IN CAMBODIA

NATIONS UNIES
BUREAU DU HAUT COMMISSAIRE
AUX DROITS DE L'HOMME AU CAMBODGE

Special Representative of the Secretary-General
for human rights in Cambodia
តំណាងពិសេសរបស់លោកអគ្គលេខាធិការទទួលបន្ទុកសិទ្ធិមនុស្សប្រចាំកម្ពុជា

OHCHR

# លោក យ៉ាស់ ហ្គាយ តំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិ ទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បញ្ចប់ទស្សនកិច្ចជាផ្លូវការលើកទីបួនរបស់លោកនៅកម្ពុជា

*ភ្នំពេញ ថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០០៧*— **លោក យ៉ាស់ ហ្គាយ** តំណាងពិសេសរបស់លោកអគ្គលេខាធិការអង្គការសហប្រជាជាតិទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា បានបញ្ចប់ទស្សនកិច្ចជាផ្លូវការលើកទីបួនរបស់លោកនៅកម្ពុជាថ្ងៃនេះ។ គោលបំណងនៃដំណើរទស្សនកិច្ចនេះ គឺលោកតំណាងពិសេសធ្វើការស្វែងយល់ថែមទៀតអំពីការវិវត្តន៍ថ្មីៗ នៅមុនការរៀបចំរបាយការណ៍លើកក្រោយរបស់លោក ដើម្បីដាក់ជូនក្រុមប្រឹក្សាសិទ្ធិមនុស្សអង្គការសហប្រជាជាតិ ដែលលោកនឹងផ្តោតលើបញ្ហាមួយចំនួន អំពីនីតិរដ្ឋ និងការទទួលបានយុត្តិធម៌។

លោកតំណាងពិសេសមានការសោកស្តាយ ដោយសារថា មិនមានសមាជិកណាម្នាក់នៃរាជរដ្ឋាភិបាលកម្ពុជា បានជួបជាមួយលោកនៅក្នុងពេលបំពេញបេសកកម្មលើកនេះទេ។ លោកតំណាងពិសេសដឹងថា លោកបានទទួលរងការរិះគន់ពីរដ្ឋាភិបាលថា លោកមិនបានធ្វើការឆ្លុះបញ្ចាំងគ្រប់ជ្រុងជ្រោយ ទៅលើហេតុការណ៍ផ្សេងៗនៅក្នុងរបាយការណ៍របស់លោក ហើយបង្ហាញទស្សនៈមួយដែលរដ្ឋាភិបាលយល់ថា យកចិត្តទុកដាក់ជ្រុលពេកចំពោះការរិះគន់របស់រដ្ឋាភិបាល។ នៅក្នុងដំណើរបេសកកម្មលើកនេះ លោកបានស្នើសុំជាមុនក្នុងការជួបប្រជុំជាមួយ នាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ រដ្ឋមន្ត្រីក្រសួងកសិកម្ម រដ្ឋមន្ត្រីក្រសួងយុត្តិធម៌ សហប្រធានក្រុមប្រឹក្សាកំណែទម្រង់ច្បាប់ និងប្រព័ន្ធយុត្តិធម៌ ក៏ដូចជាប្រធានគណៈកម្មាធិការសិទ្ធិមនុស្សរដ្ឋាភិបាល។ ប៉ុន្តែការប្រជុំទាំងនេះមិនបានកើតមានទេ ។ វាជាការពិបាកយល់ថា ការរិះគន់របស់រដ្ឋាភិបាលចំពោះលោកតំណាងពិសេស អាចទទួលបានការគាំទ្រយ៉ាងណានោះ កាលបើរដ្ឋាភិបាលបដិសេធគ្រប់ឱកាស ដើម្បីបង្ហាញពីទស្សនៈរបស់ខ្លួននោះ។ ទោះជាយ៉ាងណាក៏ដោយ លោកតំណាងពិសេសនៅតែមានឆន្ទៈចង់ជួបជាមួយរដ្ឋាភិបាល ដើម្បីពិភាក្សាអំពីស្ថានការណ៍សិទ្ធិមនុស្សនៅកម្ពុជា ក្នុងស្មារតីមិនលំអៀង និងដោយចំហ។

ក្នុងអំឡុងពេលស្នាក់នៅកម្ពុជា **លោកយ៉ាស់ ហ្គាយ** អាចជួបជាមួយតំណាងនានានៃអង្គការសង្គមស៊ីវិល គណបក្សនយោបាយ សមាជិកនៃវិជ្ជាជីវៈច្បាប់ ចៅក្រមកម្ពុជា និងចៅក្រមអន្តរជាតិនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (ECCC) ទីភ្នាក់ងារអង្គការសហប្រជាជាតិ និងសហគមន៍អ្នកការទូត។

No. 10, Street 302, Sangkat Boeng Keng Kang I, Khan Chamcar Mon, Phnom Penh, Cambodia
Tel: +(855) 23 987 671 / 987 672 / 993 590 / 993 591 or 216 342 Fax: +(855) 23 212 579 or 213 587
e-mail: cambodia@ohchr.org Website: http://cambodia.ohchr.org

លោកតំណាងពិសេសបានចាប់អារម្មណ៍ជាពិសេសចំពោះតុលាការ វិជ្ជាជីវៈច្បាប់ និងប្រព័ន្ធពន្ធនាគារ ។ លោកបានផ្ដោតលើវិសាលភាពដែលស្ថាប័នទាំងនេះអាចអនុវត្តតាមបទដ្ឋានអន្តរជាតិ និងអាចលើកកំពស់នីតិរដ្ឋ និងការពារសិទ្ធិប្រជាពលរដ្ឋកម្ពុជា ជាពិសេសក្រុមប្រជាពលរដ្ឋក្រីក្រនិងដែលងាយរងគ្រោះបំផុត ។ លោកតំណាងពិសេសបានពិនិត្យលើទិដ្ឋភាពមួយចំនួន នៃនីតិវិធីព្រហ្មទណ្ឌ ។ លោកបានពិនិត្យមើលលំអិតខ្លះដែរ នៅក្នុងអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា(ECCC) ក្នុងគោលបំណងរួមចំណែក ដើម្បីលើកកំពស់បទដ្ឋាននីតិវិធីព្រហ្មទណ្ឌ - និងការយល់ដឹងអំពីបទដ្ឋានទាំងនេះនៅក្នុងចំណោមសាធារណៈជនទូទៅ-ក្នុងការរួមជាវិភាគទាន ដើម្បីបញ្ចប់និទណ្ឌភាពចំពោះអំពើសាហាវយង់ឃ្នងលើសិទ្ធិមនុស្ស ដែលបានប្រព្រឹត្តដោយខ្មែរក្រហម ចាប់ពីឆ្នាំ១៩៧៥ ដល់ឆ្នាំ១៩៧៩។

**លោក យ៉ាស់ ហ្គាយ** បានព្យាយាមស្វែងយល់ឱ្យបានកាន់តែស៊ីជំរៅថែមទៀត អំពីបញ្ហាមួយចំនួនទាក់ទងនឹងការបណ្ដេញប្រជាពលរដ្ឋចេញពីលំនៅដ្ឋាន និងជំលោះដីធ្លី ជាពិសេសករណីទាំងឡាយដែលមានការអះអាងថា ពាក់ព័ន្ធនឹងការដកហូតយកដីធ្លីពីសហគមន៍ដោយអយុត្តិធម៌ ។ លោកបានធ្វើដំណើរទៅកាន់ខេត្តរតនគិរី ដើម្បីទទួលបានព័ត៌មានដោយផ្ទាល់អំពីជំលោះដីធ្លីនៅក្នុងខេត្តនេះ និងបានជួបជាមួយសកម្មជនសហគមន៍នានា និងមេធាវីរបស់ពួកគេ ព្រមទាំងជួបមន្ត្រីតុលាការ និងមន្ត្រីអាជ្ញាធរខេត្ត។ លោកក៏បានទៅទស្សនាពន្ធនាគារក្នុង**ក្រុងបានលុង** ដើម្បីស្វែងយល់អំពីលក្ខ-ខណ្ឌនៃការឃុំឃាំងអ្នកទោស និងអំពីធនធានដែលបានផ្ដល់សំរាប់ការគ្រប់គ្រងពន្ធនាគារ ។

លោកតំណាងពិសេសបានទៅទស្សនា ***សហគមន៍ដីក្រហម និងក្រុម៧៨*** រាជធានីភ្នំពេញ ដែលសហគមន៍ទាំងនេះ ប្រឈមមុខនឹងការគំរាមកំហែងដោយការបណ្ដេញចេញដោយបង្ខំពីលំនៅដ្ឋានរបស់ខ្លួន ។ លោកមានក្ដីកង្វល់យ៉ាងខ្លាំង ដោយមើលឃើញពីស្ថានភាពរស់នៅរបស់ប្រជាពលរដ្ឋនៅទីនោះ សូម្បីតែនៅចំកណ្ដាលរាជធានីហើយក៏ដោយ ហើយបានដឹងអំពីការភ័យខ្លាចរបស់ប្រជាពលរដ្ឋទាំងឡាយដែលកំពុងប្រឈមមុខនឹងការបណ្ដេញចេញ នៅពេលដ៏ខ្លីខាងមុខនេះ ។ លោកតំណាងពិសេសសោកស្ដាយថា អនុសាសន៍មុនៗរបស់លោកដែលស្នើឱ្យមាននីតិវិធីត្រឹមត្រូវមិនលំអៀង ដើម្បីការពារសិទ្ធិក្រុមប្រជាពលរដ្ឋដែលងាយរងគ្រោះបំផុត នៅមិនទាន់បានអនុវត្តនៅឡើយ ។ អាជ្ញាធររដ្ឋ ក៏ដូចជាក្រុមហ៊ុននានា និងបុគ្គលដែលមានទំនាក់ទំនងល្អខាងនយោបាយ បង្ហាញនូវការគោរពច្បាប់តិចតួចបំផុត ។ តិរិយាបទអសីលធម៌ចំពោះច្បាប់ បានធ្វើឱ្យខូចខាតដល់មូលដ្ឋានគ្រឹះនៃនីតិរដ្ឋ ។

លោកតំណាងពិសេស មិនមែនជាអ្នកត្រូវប្រកាសអំពីអង្គសេចក្ដីនៃរឿងក្ដីទាំងនេះនៅចំពោះមុខតុលាការទេ ។ ប៉ុន្តែអ្វីដែលគួរកត់សំគាល់នោះ គឺប្រជាពលរដ្ឋខ្វះការជឿជាក់លើតុលាការទាំងនោះ ។ ប្រជាជនមានការជឿជាក់តិចតួចថា ពួកគេនឹងបានទទួលយុត្តិធម៌ បើទោះជារឿងក្ដីរបស់ខ្លួនត្រូវបានជំនុំជម្រះក៏ដោយ ។ ចំឡែកដែរ សូម្បីតែអ្នកមានអំណាច និងអ្នកមានទ្រព្យសម្បត្តិច្រើន ក៏មានការជឿជាក់ ឬការអត់ធ្មត់តិចតួចដែរ - ពីព្រោះ ជារឿយៗ ពួកគេជួបប្រទះនូវការទាមទារតាមផ្លូវច្បាប់ ដោយការចោទប្រកាន់បកវិញពីបទបរិហារកេរ្តិ៍ ឬបទញុះញង់ ជាជាងការទុកអោយមានកិច្ចដំណើរការតាមផ្លូវច្បាប់តាមធម្មតានោះ ។ លោកតំណាងពិសេសមានកង្វល់យ៉ាងខ្លាំងដោយសារថ្មីៗនេះ មានការ

ប៉ុនប៉ងដាក់កំហិតទៅលទ្ធភាពរបស់មេធាវី ក្នុងការការពារឧត្តមប្រយោជន៍របស់កូនក្តីខ្លួន។ ជាពិសេស ការចោទប្រកាន់ពីបទញុះញង់ប្រឆាំងនឹងមេធាវីការពារជនក្រីក្រ បង្ហាញពីការប៉ុនប៉ងដោយគ្មានភស្តុតាង ដើម្បីដាក់ឱ្យទៅជាបទព្រហ្មទណ្ឌ នូវសកម្មភាពស្របច្បាប់របស់មេធាវី។

តុលាការ និងវិជ្ជាជីវៈច្បាប់មាន ឬគួរតែមានតួនាទីមួយយ៉ាងសំខាន់ក្នុងការការពារសិទ្ធិប្រជាពលរដ្ឋ។ នេះគឺជាគោលការណ៍មួយដ៏សំខាន់ដែលថា ជនគ្រប់រូបមានសិទ្ធិស្មើគ្នាចំពោះមុខច្បាប់ ។ ការពិតជាក់ស្តែង ប្រទេសទាំងអស់ប្រឈមមុខនឹងឧបសគ្គជាច្រើនក្នុងការធ្វើឱ្យសំរេចនូវឧត្តមគតិនេះ។ ប៉ុន្តែនៅកម្ពុជា គំលាតនេះគ្មានសមាមាត្រគ្នា ហាក់ដូចជាខុសគ្នាមេឃនិងដី ។ ប្រព័ន្ធនេះបានធ្វើឱ្យប្រជាជនកម្ពុជាមិនសប្បាយចិត្តឡើយ ។

លោកតំណាងពិសេសមានការភ្ញាក់ផ្អើល ដោយដឹងថា វិសាលភាពដែលជារង្វង់សកម្មភាពរបស់អង្គការក្រៅរដ្ឋាភិបាលត្រូវបានរិតត្បិតក្នុងរយៈពេលប៉ុន្មានខែថ្មីៗនេះ។ លោកបានឮការរអ៊ូរទាំជាច្រើន ពីការជ្រៀតជ្រែករបស់អង្គនីតិប្រតិបត្តិចេះតែកើនឡើង។ ការនេះធ្វើឱ្យមានការលំបាកថែមទៀត សំរាប់ស្ថាប័នទាំងនេះ ក្នុងការដើរតួនាទីដ៏សំខាន់របស់ខ្លួន ដើម្បីលើកកំពស់នីតិរដ្ឋ - តួនាទីនេះរិតតែមានសារៈសំខាន់ថែមទៀត ដោយសារប្រព័ន្ធតុលាការផ្លូវការ គ្មានប្រសិទ្ធភាពក្នុងការការពារសិទ្ធិ ។ មិនមែនតែអង្គការក្រៅរដ្ឋាភិបាលទេដែលមានការភ័យខ្លាច និងទទួលការគាបសង្កត់ពីអ្នកមានអំណាចជាច្រើននៃអង្គនីតិប្រតិបត្តិ។

ការដកហូតយកដីធ្លី និងការបណ្តេញចេញ ជួនកាលត្រូវបានដោះសារថា ជាការបើកផ្លូវសំរាប់ "ការអភិវឌ្ឍន៍ "។ ការពិតទំនងជាថា ភាពក្រីក្ររបស់ប្រជាពលរដ្ឋមួយចំនួនគឺរិតតែក្រទៅ រីឯអ្នកមានរិតតែមានថែមទៀត។ ប្រព័ន្ធច្បាប់ហាក់ជាឧបករណ៍របស់អ្នកមានទ្រព្យសម្បត្តិនិងអ្នកមានអំណាច ចំណែកឯអ្នកក្ររិតតែក្រថែមទៀត ដោយសារតុលាការបង្ហាញពីការគ្មានឆន្ទៈប្រកាន់ជំហប្រឆាំងនឹងឧបាយបញ្ឆោត និងការស៊ីសំណូក។

បញ្ហាទាំងនេះមិនមែនសំរាប់ប្រជាជនកម្ពុជាតែឯកឯងទេ។ សហគមន៍អន្តរជាតិ ដើរតួនាទីមួយសំខាន់បំផុតនៅក្នុងប្រទេសនេះ។ វាមិនគ្រប់គ្រាន់ទេ បើគ្រាន់តែនិយាយ "យើងមិនត្រូវជ្រៀតជ្រែក " នោះ។ វាមាន "ការជ្រៀតជ្រែក" រួចទៅហើយ តាមរយៈការគាំទ្ររបស់ខ្លួនចំពោះគំរោងអភិវឌ្ឍន៍ផ្សេងៗ និងតាមការជួយគាំទ្រផ្នែកហិរញ្ញវត្ថុយ៉ាងសន្ធឹកសន្ធាប់របស់ខ្លួនសំរាប់ថវិការបស់រដ្ឋាភិបាល។ អង្គការសហប្រជាជាតិ និងសហគមន៍អន្តរជាតិមានកាតព្វកិច្ច ក្នុងការធានាថា ប្រព័ន្ធដែលគេកំពុងគាំទ្រនេះមិនរំលោភលើបទដ្ឋានពិសេសនេះ ដែលសហគមន៍អន្តរជាតិប្រកាសទទួលស្គាល់ឡើយ។

កត់សំគាល់លើចំណុចវិជ្ជមានម្តង លោកតំណាងពិសេសមានសេចក្តីសោមនស្សរីករាយ ដោយឃើញថា ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមនីតិវិធីរដ្ឋប្បវេណី ដែលគេទន្ទឹងរង់ចាំជាយូរមកហើយនោះ នៅទីបញ្ចប់ ត្រូវបានចូលជាធរមាន ហើយលោកសង្ឃឹមថា ការអនុវត្តន៍នីតិវិធីថ្មីនេះនឹងផ្តល់ឱកាសសំរាប់តុលាការកម្ពុជា អនុវត្តបទដ្ឋានយុត្តិធម៌អន្តរជាតិស្របតាមកាតព្វកិច្ចអន្តរជាតិរបស់កម្ពុជា។ ច្បាប់តែមួយមុខ ជាការពិតហើយគឺមិនទាន់គ្រប់គ្រាន់នៅឡើយទេ។ លោក

តំណាងពិសេសសង្ឃឹមថា អាជ្ញាធរនឹងអនុញ្ញាត្តអោយប្រើប្រាស់ច្បាប់នេះក្នុងការផ្តន្ទាទោស ។ ដូចគ្នានេះដែរ នេះគឺមិនមែនជាកង្វះខាតច្បាប់ទេ ដែល **ប៊ិន សំណាង និងសុខសំអឿន** ត្រូវបានផ្តន្ទាទោស និងនៅតែស្ថិតក្នុងការឃុំឃាំងនៅឡើយ ទោះបីជាគ្មានភស្តុតាងដាក់បន្ទុកពីពិរុទ្ធភាពក្នុងការសំលាប់ **លោកជា វិជ្ជា** ក៏ដោយ ។

លោកសូមស្វាគមន៍ផងដែរពីការរីកចំរើនឆាប់រហ័សថ្មីៗនេះ នៃអង្គជំនុំជម្រះវិសាមញ្ញ ។ ទន្ទឹមនេះដែរ ក៏មានការវិវត្តន៍មួយចំនួន រួមមានការតែងតាំងជាថ្មីដោយអង្គនីតិប្រតិបត្តិរបស់រដ្ឋាភិបាល នូវចៅក្រមមួយរូបទៅកាន់តំណែងមួយទៀត និងការចោទប្រកាន់ថាមានអំពើពុករលួយក្នុងការជ្រើសរើសបុគ្គលិក គឺជាបុព្វហេតុនៃក្តីកង្វល់ ។ លោកតំណាងពិសេសសង្ឃឹមថា អង្គជំនុំជម្រះវិសាមញ្ញ (ECCC) ដែលជាផ្នែកមួយដ៏សំខាន់នៃប្រព័ន្ធតុលាការកម្ពុជា នឹងអនុវត្តយ៉ាងម៉ឺងម៉ាត់នូវបទដ្ឋានអន្តរជាតិ ហើយតាមរយៈនេះវានឹងធ្វើជាគំរូល្អមួយឱ្យតុលាការដទៃទៀតក្នុងស្រុកអនុវត្តតាម ។លោកបានពិភាក្សាជាមួយចៅក្រម និងមន្ត្រីជាច្រើន អំពីវិធីផ្សេងៗដែលធ្វើអោយការងាររបស់អង្គជំនុំជម្រះវិសាមញ្ញ ក្លាយទៅជាការពិត ដែលមានឥទ្ធិពលជាវិជ្ជមានដល់សតិសម្បជញ្ញៈរបស់ប្រជាជន ក៏ដូចជាដំណើការនៃប្រព័ន្ធច្បាប់ ។ ទោះជាយ៉ាងណា លោកមានអារម្មណ៏ថា ប្រសិទ្ធភាពនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងការបញ្ចប់និទណ្ឌភាព នឹងត្រូវរិចរិល ដោយសារតែការកំណត់នៅក្នុងចំណាត់ការរបស់ខ្លួនចំពោះតែបុគ្គលមួយចំនួនដែលបានព្រមព្រៀងគ្នាដោយនយោបាយនោះ ។

លោកតំណាងពិសេស នឹងចេញរបាយការណ៏លើកក្រោយរបស់លោក នៅដើមឆ្នាំ២០០៨ ហើយលោកនឹងដាក់របាយការណ៏នេះ ជូនក្រុមប្រឹក្សាសិទ្ធិមនុស្ស នៅទីក្រុងហ្សឺណែវក្នុងខែមីនា ឆ្នាំ២០០៨ ខាងមុខនេះ ។

End.